ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថាប័នប្រឆាំងអំពើពុករលួយ
**អង្គភាពប្រឆាំងអំពើពុករលួយ**
លេខ ០៥៤/២៦ សសរ អ.ប.ព.

# សេចក្ដីសម្រេច
# ស្ដីពី
# ការទទួលស្គាល់សមាសភាពអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត
# សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ នៅខេត្តឧត្តរមានជ័យ

## ទេសរដ្ឋមន្ត្រី ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- យោងសេចក្ដីសម្រេចលេខ ០២៩/២៦ ស.រ អ.ប.ព. ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៦ ស្ដីពីការបង្កើតក្រុមការងារដឹកនាំការងារសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦
- យោងសេចក្ដីជូនដំណឹងលេខ ០០៤/២៦ ស.ជ.ណ អ.ប.ព. ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦ ស្ដីពីការជ្រើសរើសអ្នកសង្កេតការណ៍ស្ម័គ្រចិត្តសម្រាប់ការសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ដែលបានកំណត់អំពីចំនួនអ្នកសង្កេតការណ៍ស្ម័គ្រចិត្តរបស់ អ.ប.ព. នៅតាមរាជធានី-ខេត្តនីមួយៗ អំពីលក្ខខណ្ឌចុះឈ្មោះជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត (មានអាយុចាប់ពី ២១ ឆ្នាំឡើងទៅ - និស្សិត ឬបុគ្គលផ្សេងទៀតក្រៅពីព្រះសង្ឃ (កំពុងគង់ចាំព្រះវស្សា) គ្រូបង្រៀន មន្ត្រីរាជការសាធារណៈ និងអ្នកសារព័ត៌មាន - មិនត្រូវចូលរួមសង្កេតការណ៍ក្នុងមណ្ឌលប្រឡងដែលមានបងប្អូន សាច់ញាតិ ឬមិត្តភ័ក្តិជាបេក្ខជនប្រឡងដែលនេះជាទំនាស់ផលប្រយោជន៍ - ត្រូវឬធ្លាប់បានចូលរួមវគ្គបណ្ដុះបណ្ដាល/កិច្ចប្រជុំផ្សព្វផ្សាយ ស្ដីពីការងារសង្កេតការណ៍ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ - ត្រូវទាញយកកម្មវិធី Angkor Life មកប្រើប្រាស់សម្រាប់ការជូនដំណឹង និងTelegram សម្រាប់ទំនាក់ទំនងការងារសង្កេតការណ៍ - មានមធ្យោបាយ ធនធានពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញការងារសង្កេតការណ៍ស្ម័គ្រចិត្តដោយខ្លួនឯង រួមទាំងមធ្យោបាយធ្វើដំណើរ - គោរពតាមច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋានគតិយុត្តជាធរមាន ការចាត់តាំង ដឹកនាំ ប្រគល់ភារកិច្ចរបស់ក្រុមដឹកនាំសង្កេតការណ៍ថ្នាក់កណ្ដាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល ជាពិសេសគោរពបានយ៉ាងខ្ជាប់ខ្ជួនបទប្បញ្ញត្តិ សេចក្ដីណែនាំ យល់តួនាទីភារកិច្ចអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត និងអំពីលក្ខខណ្ឌសម្រេចជ្រើសរើសបេក្ខជន (អាទិភាពជ្រើសរើសបេក្ខជនដាក់ពាក្យមុន - និស្សិតកំពុងសិក្សាតាមគ្រឹះស្ថានសិក្សានានា - មិនធ្លាប់ចូលរួមសង្កេតការណ៍ - អាទិភាពនារី - មានអាយុច្រើន)
- យោងតម្រូវការចាំបាច់នៃការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ

## សម្រេច

**ប្រការ ១._**

**ខេត្តឧត្តរមានជ័យ** មានអ្នកដាក់ពាក្យជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្តសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ចំនួន ៤១ នាក់ (អ្នកដាក់ពាក្យ)។ សម្រាប់ខេត្តឧត្តរមានជ័យ អង្គភាពប្រឆាំងអំពើពុករលួយ (អ.ប.ព.) មានគម្រោងជ្រើសរើសអ្នកសង្កេតការណ៍ចំនួន ៤៨ នាក់ (ហៅថាអ្នកសង្កេតការណ៍)។

ក្នុងចំណោមអ្នកបានដាក់ពាក្យចំនួន ៤១ នាក់ អ.ប.ព. បានពិនិត្យឃើញថា មានអ្នកដាក់ពាក្យ ចំនួន ១៣ នាក់ ដែលមិនបានបំពេញគ្រប់តាមលក្ខខណ្ឌ ហេតុដូចនេះ អ.ប.ព. ទទួលបានអ្នកសង្កេតការណ៍គ្រប់លក្ខខណ្ឌចំនួន ២៨ នាក់។

**ប្រការ ២._**

ទទួលស្គាល់សមាសភាពអ្នកសង្កេតការណ៍សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ នៅខេត្តឧត្តរមានជ័យ ចំនួន ២៨ នាក់។

| ល.រ. | | គោត្តនាម-នាម | ភេទ |
|---|---|---|---|
| **១. មណ្ឌលវិទ្យាល័យហ៊ុនសែនឧត្តរមានជ័យ ត្បូង** | | | |
| 1 | 1 | សួន ចំរើន | ប្រុស |
| 2 | 2 | សេន ស្រីពេជ | ស្រី |
| 3 | 3 | អិល ស្រីអូន | ស្រី |
| 4 | 4 | ឡឹប លូន | ប្រុស |
| **២. មណ្ឌលវិទ្យាល័យតេជោសែន សំរោង** | | | |
| 5 | 1 | ហែម កែវ | ស្រី |
| 6 | 2 | ប៉ោង ពៅ | ស្រី |
| 7 | 3 | រុំ តុលា | ប្រុស |
| 8 | 4 | ព្រឿង សុឃីម | ស្រី |
| 9 | 5 | រដ្ឋា បូរ៉ា | ប្រុស |
| 10 | 6 | នឹម ហេងលីដា | ស្រី |
| 11 | 7 | ថា រ៉ាដូ | ប្រុស |
| 12 | 8 | ហង់ យូហាន | ប្រុស |
| 13 | 9 | ហ៊ិន ឈាងម៉ៃ | ប្រុស |
| 14 | 10 | ភាព ផលទ្បៃ | ស្រី |
| 15 | 11 | ឃ្លី យាន់ | ប្រុស |
| 16 | 12 | ណន សីឡា | ស្រី |
| 17 | 13 | ហៀប សុជា | ស្រី |
| 18 | 14 | ធា សុធួយ | ប្រុស |
| 19 | 15 | ភ្លៀត សីហា | ប្រុស |
| 20 | 16 | យុត គឹមហូរ | ប្រុស |
| 21 | 17 | អាន ជីវ៉ា | ស្រី |
| **៣. មណ្ឌលវិទ្យាល័យហ៊ុនសែនឧត្តរមានជ័យ លិច** | | | |
| 22 | 1 | ខ្ទឹង ស្រីនិច | ស្រី |
| 23 | 2 | ថុន សាំឆាយ | ស្រី |
| 24 | 3 | បួត ស្រីដាវ | ស្រី |
| 25 | 4 | អ៊ឹង ស្រីពេជ្រ | ស្រី |
| 26 | 5 | អេង ស៊ីណាំ | ស្រី |
| 27 | 6 | ជិក សុជឿន | ស្រី |
| 28 | 7 | ឡូន មករា | ស្រី |

**ប្រការ ៣._**

អ្នកសង្កេតការណ៍ស្ម័គ្រចិត្តស្ថិតក្រោមការចាត់តាំង ដឹកនាំ និងប្រគល់ភារកិច្ចរបស់ក្រុមការងារដឹកនាំសង្កេតការណ៍ថ្នាក់កណ្តាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល។

អ្នកសង្កេតការណ៍ស្ម័គ្រចិត្តត្រូវបំពេញភារកិច្ចឱ្យបានខ្ជាប់ខ្ជួនអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន មានជាអាទិ៍ឧបសម្ព័ន្ធ២ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ កាតព្វកិច្ច និងវិន័យ សម្រាប់អ្នកសង្កេតការណ៍ស្ម័គ្រចិត្តនៃសេចក្តីណែនាំ ស្តីពីការងារសង្កេតការណ៍របស់អង្គភាពប្រឆាំងអំពើពុករលួយលើដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦។

ប្រការ ៤._

ក្រុមការងារដឹកនាំសង្កេតការណ៍ថ្នាក់កណ្តាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល សាមីខ្លួនដូចមានក្នុងប្រការ ២ ខាងលើ និងផ្នែកពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០២៦

ទេសរដ្ឋមន្ត្រី

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

កិត្តិនីតិកោសលបណ្ឌិត ឱម យ៉ិនទៀង

**<u>កន្លែងទទួល៖</u>**

- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ



អគារលេខ ៥៤ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Website: www.acu.gov.kh, E-mail: complaint@acu.gov.kh, info@acu.gov.kh
Tel: 023 223 954, 023 221 653, Hotline: 1282